बुद्धस्तुतिः

Buddhastutiḥ

(A short poem in Sanskrit with Khmer translation)



Poem authored and published by

Prof. Dr. C. Upender Rao

Visiting Professor of Sanskrit and Buddhist Studies,
Phnom Penh, Cambodia

November 2016

बुद्धस्तुतिः

Buddhastutiḥ

is a Sanskrit poem, which describes the noble qualities of

Bhagavān Buddha

in a lucid Sanskrit language. This poem also describes the importance of teachers in Indian culture and the highest place of Bhagavān Buddha among them.

For the convenience of Cambodian people, it has been translated into Khmer language by Mr. Khatna Pi.


Prof. C. Upender Rao

Author of the poem

ពុទ្ធស្តុតិះ

(បទសសើរចំពោះព្រះសព្វញ្ញុពុទ្ធ)

(កាព្យសំស្រ្កឹតជាមួយនឹងបំណកប្រែជាភាសាខ្មែរ)



និពន្ធដោយ

សាស្ត្រាចារ្យបណ្ឌិត.ឆោដូរី. ឧបេន្ទ្រ រាវ

សាស្ត្រាចារ្យទស្សនកិច្ច, ភ្នំពេញ,

កម្ពុជា

ពុទ្ធស្តុតិះ

(បទសសើរចំពោះព្រះសព្វញ្ញុពុទ្ធ)

(កាព្យសំស្ក្រឹតអមដោយបំណកប្រែជាភាសាខ្មែរ)

និពន្ធដោយ

ឆៅដូរី. ឧបេន្ទ្រ រ៉ាវ

សាស្ត្រាចារ្យបណ្ឌិត

សាស្ត្រាចារ្យទស្សនកិច្ច, ភ្នំពេញ,

កម្ពុជា

សាស្ត្រាចារ្យភាសា បាលី និងសំស្ក្រឹត

នៃមជ្ឈមណ្ឌលពិសេសសម្រាប់ការសិក្សាភាសាសំស្ក្រឹត

នៅសាកលវិទ្យាល័យ

Jawaharlal Nehru   ក្នុងទីក្រុង ញូវ ដេលី, ប្រទេសឥណ្ឌា

ពុទ្ធស្តុតិះ

(បទសសើរចំពោះព្រះសព្វញ្ញូពុទ្ធ)

(កាព្យសំស្ក្រឹតអមដោយបំណាកប្រែជាភាសាខ្មែរ)

Buddhastutiḥ

(A short poem in Sanskrit with Khmer translation)

Buddhastutiḥ *is a Sanskrit poem, which describes the noble qualities of* ***Lord Buddha*** *in a lucid Sanskrit language. This poem also describes the importance of teachers in Indian culture and the highest place of Lord Buddha among them. For the convenience of Cambodian people, it has been translated into Khmer language.*

First edition : November 2016

Type Setting- Khatna Pi (RUPP)

Cover page desinged by author

Poem publishsd by

PROF. DR. C. UPENDER RAO

Visiting Professor of Sanskrit and Buddhist Studies, Phnom Penh, Cambodia



សម្មោទនីយកថា


បន្ទាប់ពីបានអាននិងពិនិត្យដោយយកចិត្តទុកដាក់មក អាត្មាភាពបានទ្រង់យល់ឃើញថា **កាព្យពុទ្ធស្តុតិ** (ការសរសើរតម្កើងព្រះសម្មាសម្ពុទ្ធ) នេះពិតជាបានជាហិតានុហិតប្រយោជន៍សម្រាប់ប្រជាពុទ្ធបរិស័ទគ្រប់ទិសទីបានសិក្សារៀនសូត្រ។

អាត្មាភាព សូមកោតសរសើរចំពោះវិរិយភាពលោកសាស្ត្រាចារ្យ បណ្ឌិត **ឆៅដូរី ឧបេន្ទ្រ រ៉ាម** និងសូមជូនពរ លោកសាស្ត្រាចារ្យបណ្ឌិត ដែលបានខិតខំព្យាយាមប្រឹងប្រែងរៀបរៀងសៀវភៅ **កាព្យពុទ្ធស្តុតិ** បានចប់ជាស្ថាពរ។ ដោយតេជានុភាពនៃគុណព្រះរតនត្រៃ សូមលោកបណ្ឌិតបានប្រកបតែនឹងព្រះពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

បានទ្រង់ព្រះបរមរាជានុញ្ញាត និងអនុញ្ញាតឲ្យបោះពុម្ពផ្សាយជាផ្លូវការ។

ថ្ងៃ សុក្រ ១១ រោច ខែ កត្តិក ឆ្នាំ វក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០

ព្រះហត្ថលេខា



សម្ដេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត កិត្តិឧទ្ទេសបណ្ឌិត
សម្ដេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា



អារម្ភកថា

បន្ទាប់ពីបានអានរួចមក តាមមតិផ្ទាល់របស់ខ្ញុំ យល់ឃើញថា សៀវភៅមានចំណងជើងថា **ពុទ្ធស្តុតិះ** ដែលជាស្នាដៃរបស់ **លោកសាស្ត្រាចារ្យ បណ្ឌិត នៅដូរី ឧបេន្ទ្រ រ៉ាវ** សរសេរជាបទកាព្យសំស្ក្រឹតហើយបានបកប្រែមកជាខេមរភាសាស្តីពីការ សរសើរចំពោះគុណព្រះពុទ្ធជាម្ចាស់ គឺមានអត្ថន័យ និងអត្ថរសល្អ សម្រាប់ព្រះសង្ឃ ឧបាសក ឧបាសិកា ក៏ដូចជាពុទ្ធសាសនិកទូទៅរៀនសូត្រ ។ តាមមតិរបស់ខ្ញុំ សៀវភៅនេះគួរតែត្រូវបានបោះពុម្ពផ្សាយឲ្យបានទូលំទូលាយ ដើម្បីបានជាគុណប្រយោជន៍ដល់សាធារណៈជនគ្រប់មជ្ឈដ្ឋាន ។

លោកសាស្ត្រាចារ្យ បណ្ឌិត នៅដូរី ឧបេន្ទ្រ រ៉ាវ គឺជាសាស្ត្រាចារ្យពីខាងក្រៅដែលមានចំណេះដឹងជ្រៅជ្រះ ជាពិសេសផ្នែកព្រះពុទ្ធសាសនា ភាសាបាលី និងភាសាសំស្ក្រឹត ដែលបានអញ្ជើញមកពីឥណ្ឌាតាមរយៈ ICCR ។ ក្នុងរយៈកាលនៃការបំពេញការងារនៅក្នុងពុទ្ធិកសាកលវិទ្យាល័យ លោកសាស្ត្រាចារ្យ មានសេចក្តីព្យាយាមខ្ពស់ក្នុងការបង្ហាត់បង្រៀនសមណនិស្សិត-និស្សិត ជាពិសេសបានបង្កើតស្នាដៃនេះឡើង ដែលមានអត្ថប្រយោជន៍ដ៏ឧត្តុង្គឧត្តមដល់ពុទ្ធសាសនិកខ្មែរយើង។

ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះលោកសាស្ត្រាដែលបានខិតខំ ព្យាយាម បង្កើតស្នាដៃនេះឡើង ដើម្បីបានជាឧត្តមប្រយោជន៍នៃព្រះពុទ្ធសាសនាខ្មែរយើង។ ទន្ទឹមជាមួយនឹងគ្នានេះដែរ ខ្ញុំក៏សូមជូនពរដល់លោក សាស្ត្រចារ្យ ឲ្យទទួលបាននូវពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណ សុខ និង ពល កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឲ្យព្រះពុទ្ធសាសនាតាំងនៅអស់កាលដ៏យូរ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦

ហត្ថលេខា

ព្រះធម្មឃោសាចារ្យ បណ្ឌិត យី សុវណ្ណរតនា

ព្រះសាកលវិទ្យាធិការស្តីទី

នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ



វាចារបស់ខ្ញុំ!

សៀវភៅឈ្មោះ "ពុទ្ធស្តុតិ:" ដែលនិពន្ធដោយ លោកសាស្ត្រាចារ្យបណ្ឌិត **ឆៅដូរី. ឧបេន្ទ្រ រ៉ាច** នេះ មានអត្ថន័យនិងខ្លឹមសារល្អគួរឲ្យចាប់អារម្មណ៍ណាស់ ជាពិសេស ខ្លឹមសារដែលទាក់ទងទៅនឹងការអប់រំសិស្សឲ្យស្គាល់អំពីគុណតម្លៃ របស់គ្រូអាចារ្យអ្នកបង្រៀន។


ខ្ញុំសូមកោតសរសើរយ៉ាងក្រៃលែង ចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **ឆៅដូរី ឧបេន្ទ្រ រ៉ាច** ដែលបានខិតខំប្រឹងប្រែងតែងនិពន្ធសៀវភៅនេះឡើង ដ៏ប្រដាប់ ដោយពាក្យស្លោកជាភាសាសំស្ក្រឹតនិងការបកប្រែជាភាសាខ្មែរ ដើម្បីទុកជាមត៌កដ៏សំខាន់សម្រាប់កុលបុត្រកុលធីតាខ្មែរអ្នកអានគ្រប់ជំនាន់ ឲ្យបានក្រេបជញ្ជក់នូវអត្ថរសអំពីស្នាដៃដ៏តូចមួយនេះ។

ទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការ ចូរកើតមានដល់លោកសាស្ត្រាចារ្យបណ្ឌិត **ឆៅដូរី ឧបេន្ទ្រ រ៉ាច** ព្រមទាំងសម្រេចបាននូវពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញ,ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

សាស្ត្រាចារ្យភាសាបាលី-សំស្ក្រឹត

មហា ឧត្តមវីរិយោ



ហ៊ុំ សុទ្ធា

អំពីកវី



សាស្ត្រាចារ្យបណ្ឌិត .**នៅជូរី. ខ្ញបេន្ទ្រ រ៉ាច** គឺជាប្រធាន មជ្ឈមណ្ឌលសិក្សាភាសាសំស្ក្រឹត នៅសាកលវិទ្យាល័យ Jawaharalal Nehru ក្នុងទីក្រុង New Delhi។ មុនពេលមកកាន់ប្រទេសកម្ពុជា ក្នុងនាមជា សាស្ត្រាចារ្យទស្សនកិច្ច (Visiting professor), គាត់បានបញ្ចប់ការសិក្សាថ្នាក់ អនុបណ្ឌិត ផ្នែកសិល្បៈ និងទស្សនវិជ្ជាភាសាសំស្ក្រឹត ព្រមទាំងថ្នាក់អនុបណ្ឌិតខាង សិល្បៈ និងបណ្ឌិតខាងទស្សនៈវិជ្ជាជាភាសាបាលី រួមទាំងការសិក្សាផ្នែកខាង ព្រះពុទ្ធសាសនាផងដែរ។ លោកក៏បានបញ្ចប់នូវការសិក្សាថ្នាក់បរិញ្ញាបត្រការអប់រំ ព្រមទាំងទទួលបាននូវសញ្ញាបត្រការសិក្សាថ្នាក់បឋម និងកម្រិតខ្ពស់ខាងភាសា ប្រាក្រឹត្យនិងអក្សរសាស្ត្រ។ លោកបានកាន់តំណែងជាសាស្ត្រាចារ្យបណ្ឌិតនិងបង្ហាត់បង្រៀននៅ "មជ្ឈមណ្ឌលពិសេសសម្រាប់ការសិក្សាភាសាសំស្ក្រឹត" នៅ សាកលវិទ្យាល័យJawaharalal Nehru ក្នុងទីក្រុង New Delhi។

សាស្ត្រាចារ្យ **រ៉ាច** បានរៀបចំសន្និសីទជាតិនិងអន្តរជាតិជាច្រើន។ ក្នុងឆ្នាំ ២០១៤ លោកបានរៀបចំសន្និសីទជាតិដែលទាក់ទងនង «ភាសាបាលីនិងវប្បធម៌ឥណ្ឌា»។ លោកបានសរសេរនិងបោះពុម្ពសៀវភៅជាភាសាសំស្ក្រឹត ហិណ្ឌូ តេលុគុ និងភាសាអង់គ្លេស។ គាត់បង្រៀនភាសាបាលីនិងអក្សរសាស្ត្រនៅសាកលវិទ្យាល័យ Banaras Hindu university និងភាសាសំស្ក្រឹតរួមទាំងអក្សរសាស្ត្រនៅ សាកលវិទ្យាល័យ Osmania ក្នុងទីក្រុង Hyderabad ដែលបច្ចុប្បន្នស្ថិតនៅក្នុងរដ្ឋ Telangana ក្នុងប្រទេសឥណ្ឌា។

លោកបានទទួលនូវពានរង្វាន់ ព្រមទាំងសញ្ញាប័ត្រកិត្តិយសពីស្ថាប័ននានាទាំងក្នុងប្រទេសឥណ្ឌានិងក្រៅប្រទេស។ លោកបានទទួលពានរង្វាន់«Delhi Gsurav» ពីParvateeya Vikasa Samiti នៅទីក្រុងដេលី។ លោកបានទទួលនូវប័ណ្ណសរសើរពីសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញក្នុងប្រទេសកម្ពុជា។ លោកក៏បានទទួលពានរង្វាន់ «Kadambari»ពីAkhila Bharateeya Vidvat Parishad នៅ Kashi ពីការនិពន្ធ Vangmaya Vallari ជាភាសាសំស្ក្រឹត។

លោកទទួលបានមេដាយមាសចំនួន៣ ពីសាកលវិទ្យាល័យ Osmania និងសាកលវិទ្យាល័យBanaras Hindu University សម្រាប់ចំណាត់ថ្នាក់ឆ្នើមរបស់លោកនៅក្នុងវិស័យអប់រំ។ លោកបានទទួលនូវពានរង្វាន់«Vidya Sagar»ពីវិទ្យាស្ថាន Oriental នៅKalkata ក្នុងឆ្នាំ២០១៥ និង២០១៦។ គាត់បានបោះពុម្ពសៀវភៅចំនួន ១៦ក្បាល អត្ថបទព្រមទាំង ឯកសារស្រាវជ្រាវជាច្រើនផងដែរ។

សាស្ត្រាចារ្យ **រ៉ាវ** មានជំនាញផ្នែកភាសាសំស្ក្រឹតរួមទាំងភាសាបាលី និងមានការចាប់អារម្មណ៍ទៅលើការស្រាវជ្រាវអក្សរសាស្ត្រសំស្ក្រឹត កំណាព្យ អក្សរសិល្ប៍ ព្រះពុទ្ធសាសនា និងទស្សនវិជ្ជាជាដើម។ លោកមានជំនាញក្នុងការបង្រៀន និងនិយាយភាសាសំស្ក្រឹត។ បច្ចុប្បន្នសាស្ត្រាចារ្យ **រ៉ាវ** គឺជាសាស្ត្រាចារ្យទស្សនកិច្ចក្នុងប្រទេសកម្ពុជាក្រោមកម្មវិធី ICCRរបស់ប្រទេសឥណ្ឌា។

សាស្ត្រាចារ្យ **រ៉ាវ** បានកាន់តំណែងផ្នែករដ្ឋបាលនានា។ លោកជាសមាជិកទូទៅនៅក្នុងI.C.P.R។ លោកជាអ្នកស្រាវជ្រាវក្នុងI.U.Cដែលស្ថិតក្នុង«វិទ្យាស្ថាននៃការសិក្សាកម្រិតខ្ពស់ប្រទេសឥណ្ឌា» Shimla, Himachal Pradesh។ លោកជាសាស្ត្រាចារ្យទស្សនកិច្ចក្នុងសាកលវិទ្យាល័យជាតិបណ្ឌិតសភា Keiv Mohyla ដែលស្ថិតក្នុងប្រទេសUkrain, សាកលវិទ្យាល័យរដ្ឋទីក្រុង Moscow ក្នុងប្រទេស Russia, សាកលវិទ្យាល័យរដ្ឋ St Petersburg ក្នុងប្រទេស Russia និងL.N. Gumilyov សាកលវិទ្យាល័យជាតិ Eurasian, Astana, Kazakhstan និងបង្រៀនភាសាសំស្ក្រឹតទស្សនវិជ្ជាព្រះពុទ្ធសាសនានៅទីនោះ។ លោកគឺជាសមាជិកមួយរូបនៃក្រុមបកប្រែក្រោមគម្រោងបេតិកភ័ណ្ឌ Khyentse Foundation អក្សរសាស្ត្រពុទ្ធសាសនានៅសហរដ្ឋអាមេរិកនិងបានបកប្រែគម្ពីរមហាយានសូត្រ ពីសំស្ក្រឹតទៅជាភាសាអង់គ្លេស។ I.C.P.R និង Rastriya Sanskrit Sasnsthan ទីក្រុងNew Delhi បានផ្តល់គម្រោងបកប្រែទៅលោកសាស្ត្រាចារ្យ **.វេជ្ជ. ចន្ទ្រា រ៉ាវ** បានបញ្ចប់នូវ គម្រោង U.G.C ជាការស្រាវជ្រាវសំខាន់មួយ ដែលមានចំណងជើងថា Pali Sabda-Kalpataruh (វចនានុក្រមសង្ខេបពី ភាសាបាលី ទៅ ភាសា Odia និងភាសាTelugu)។

ពុទ្ធគុរុប្រគំសា

(បទសសើរព្រះពុទ្ធបរមគ្រូ)

សារៈសំខាន់នៃគ្រូបង្រៀនពីសម័យបុរាណ :

ក្នុងរយៈពេលដ៏យូរលង់មួយ មហាគុរ៉ាចារ្យទាំងឡាយបានធ្វើឲ្យរដ្ឋឥណ្ឌាក្លាយជារដ្ឋគំរូមួយសម្រាប់ប្រទេសដទៃទៀត។ នៅពេលនោះទំនាក់ទំនងរវាងគ្រូនិងសិស្សគណាគឺបរិសុទ្ធណាស់។ គ្រូអាចារ្យជាច្រើន ពីអតីតកាលបានចូលនៅក្នុងបណ្ដាប្រទេសផ្សេងទៀត ហើយផ្សព្វផ្សាយចំណេះដឹងដ៏ខ្ពស់បំផុត។

បុព្វបុរសទាំងឡាយ បានចាត់ទុកថាគ្រូទាំងអស់របស់ពួកគេគឺជាបុគ្គលដ៏មានសារៈសំខាន់ណាស់។ ដូចជាព្រះរាមបានគោរពបូជាមហាគុរុរបស់ព្រះអង្គគឺ មហាឫសីវាសិឬ ។ កម្លាំងឫទ្ធិរបស់មហាឫសីវាសិឬមានភាពខ្ពង់ខ្ពស់រហូតធ្វើឲ្យមហាឫសី វិស្វាមិត្រ ព្យាយាមធ្វើឲ្យស្មើនឹងគាត់។ មហាគុរុនាកាលខាងក្រោយមកដូចជា មហាឫសីវាល្មិកិ,មហាឫសីវ្យាសៈបានបង្ហាញកំពូលចំណេះរបស់ពួកលោកដោយការសរសេរកំណាព្យយ៉ាងល្អអស្ចារ្យដូចជា រាមាយណៈ និង មហាភារតៈ។ គ្រូបង្រៀនត្រូវបានគេគោរពបូជាយ៉ាងខ្លាំង។ នៅក្នុងព្រះពុទ្ធសាសនាឋានៈរបស់គ្រូបង្រៀនគឺមានកម្រិតខ្ពស់ណាស់។

មានគ្រូដ៏អស្ចារ្យជាច្រើនក្នុងពិភពលោកនេះ ប៉ុន្តែម្ចាស់ព្រះពុទ្ធជាម្ចាស់អាចចាត់ទុកថាជាអ្នកត្រួសត្រាយក្នុងចំណោមពួកគេទាំងអស់។ ព្រះពុទ្ធបរមគ្រូមានសាវ័កជាច្រើនដែលតែងតែធ្វើដំណើរតាមព្រះអង្គនៅតាមដងផ្លូវនិងរាជាណាចក្រនានា។ ព្រះពុទ្ធបរមគ្រូបានបង្រៀន ពួកគេអំពីសភាវៈប្រែប្រួលមិនទៀងទាត់នៃរាងកាយហើយសូមឲ្យមនុស្សទាំងឡាយស្វែងយល់ដោយខ្លួនឯង។ មនុស្សទាំងអស់បានស្លាប់ទៅនៅក្នុងអវិជ្ជានិងចំណងនៃលោក។ គេអាចសម្លាប់អវិជ្ជាបានជាមួយនឹងពន្លឺនៃចំនេះដឹងពិតតែប៉ុណ្ណោះ។

សព្វថ្ងៃនេះយើងប្រឈមមុខនឹងបញ្ហាផ្សេងៗដោយសារតែការភ្លេចពីសារៈសំខាន់នៃគ្រូ។ ហេតុនេះហើយ យើងគួរតែមានការយល់ដឹងអំពីគុណសម្បត្តិរបស់គ្រូបង្រៀន និងផ្ដល់ការគោរពចំពោះពួកគាត់។

ពុទ្ធគុរុប្រសំសា

(បទសសើរព្រះពុទ្ធបរមគ្រូ)

1. विद्या ददाति विनयं विद्यां यच्छति सद्गुरुः ।
विद्याधीनं हि विनयं गुर्वधीना हि सा मता ॥

១, វិទ្យា ទទាតិ វិនយំ វិទ្យាំ យច្ឆតិ សទ្គុរុះ ។
វិទ្យាធីនំ ហិ វិនយំ គុវ៌ធីនា ហិ សា មតា៕

១. ចំណេះវិជ្ជានាំមកនូវវិន័យ ហើយចំណេះវិជ្ជានោះសោតត្រូវបានបង្ហាត់បង្ហាញដោយគ្រូទៅកាន់សិស្ស។ បើដូច្នេះវិន័យបានមកដោយសារចំណេះវិជ្ជា ហើយចំណេះវិជ្ជាបានមកតាមរយៈគ្រូបង្រៀន។

2. तस्माद्गुरुमुपास्यैव सिद्धिं विन्देयुरन्यथा ।
नरास्स्वस्थानतो भ्रष्टास्तर्ज्यन्तेऽन्यैरहर्निशम् ॥

២, តស្មាទ្គុរុមុបាស្យៃវ សិទ្ធិំ វិន្ទេយុរន្យថា ។
នរាស្វស្ថានតោ ភ្រឞ្ដាស្តជ៌្យន្តេ៝ន្យៃរហនិ៌ឝម៑៕

២. ព្រោះហេតុនោះ ជនទាំងឡាយដែលអាចសម្រេចនូវប្រយោជន៍ទាំងពួងបានមានតែតាមរយៈការគោរពប្រណិប័តន៍គ្រូរបស់ពួកគេប៉ុណ្ណោះ។ បើមិនដូច្នេះទេពួកគេនឹងបាត់បង់នូវបំណាងប្រាថ្នា ហើយនឹងត្រូវបានស្តីបន្ទោសដោយអ្នកដទៃទាំង ពេលថ្ងៃ និងពេលយប់។

3. यत्राचार्याः प्रपूज्यन्ते रमन्ते तत्र देवताः ।
यत्रैतेषामवज्ञा स्यात्क्रियास्तत्राफला मताः ॥

៣,   **យត្រាចាយ៌ាះ ប្របុជ្យន្តេ រមន្តេ តត្រ ទេវតាះ។**

យត្រៃតេឞាមបជ្ជា សព្វាត្រ្កិយាស្តត្រាផលា មតាះ៕

៣.   ទេវតាទាំងឡាយ នឹងស្ថិតនៅថែរក្សាតែក្នុងទីកន្លែងដែលគ្រូត្រូវបានគេ គោរពបូជាតែប៉ុណ្ណោះ កន្លែងណាដែលគ្រូត្រូវបានគេត្មិះតិះដៀលនោះ សកម្មភាពទាំងឡាយនឹងក្លាយទៅជាគ្មានបានផ្លែផ្កាអ្វីឡើយ។

4.   वेदास्संसारमोहघ्नाः प्रशंसन्ति गुरुं सदा ।

आचार्यवर्यस्स भवेद्यस्सदा छात्रवत्सलः ॥

៤,   **វេទាស្សំសារមោហឃ្នាះ ប្រឝំសន្តិ គុរុំ សទា។**

អាចាយ៌វយ៌ស្ស ភវេទ្យស្សទា ឆាត្រវត្សលះ៕

៤.   វេទ ដែលជាអ្នកលុបបំបាត់ចោលនូវភាពងងឹតអន្ធការនៃសំសារនោះ បានសរសើរលើកតម្កើងគ្រូជានិច្ច, គ្រូដែលស្រឡាញ់និងមានមេត្តាករុណាចំពោះសិស្ស គឺជាគ្រូបង្រៀនដ៏ខ្ពង់ខ្ពស់។

5.   यस्त्यक्त्वान्यानि कार्याणि मग्नस्सारस्वते महे ।

तुष्टान्तरङ्गस्सततं गुरुरित्यभिधीयते ॥

៥,   **យស្ត្យក្ត្វាន្យានិ កាយ៌ាណិ មគ្នស្សារស្វតេ មហេ។**

តុឞ្ដាន្តរង្គស្សតតំ គុរុរិត្យភិធីយតេ៕

៥.   អ្នកណាមួយ ដែលលះបង់នូវរាល់សកម្មភាពទាំងឡាយទាំងពួង ហើយជាប់ចិត្តយ៉ាងជ្រាលជ្រៅទៅក្នុងពិធីការនៃការអប់រំ និងមានមនសិការនៅក្នុងបេះដូង អ្នកនោះឯងទើបហៅពេញបានថាជា គ្រូបង្រៀន។

6.	गुरुसेवारतश्शान्तः गुर्वाज्ञायत्तचिन्तनः ।
सदा शान्तस्तुष्टचित्तश्छात्र इत्यभिधीयते ॥

**៦,	គុរុសេវារតឝ្ឝាន្តះ គុវ៌ាជ្ញាយត្តចិន្តនះ**

សទា ឝាន្តស្តុឞ្ដចិត្តឝ្ឆាត្រ ឥត្យភិធីយតេ៕

៦.	អ្នកណាមួយ ដែលពេញចិត្តនឹងការឧបដ្ឋាកបម្រើគ្រូ ហើយផ្ដោតចិត្តគំនិតរបស់ខ្លួនដើម្បីបំពេញតាមអាជ្ញារបស់គ្រូ គឺតែងតែសប្បាយរីករាយបង្កប់នៅក្នុងបេះដូង, អ្នកនោះឯងទើបហៅពេញបានថា ជាសិស្ស។

7.	न हि ज्ञानेन सदृशं पवित्रं विद्यते भुवि ।
तत्प्रदाता गुरुश्श्रेष्ठश्शिष्यश्श्रेष्ठस्तदाश्रितः ॥

**៧,	ន ហិ ជ្ញានេន សទ្ឫឝំបវិត្រំ វិទ្យតេ ភុវិ។**

តត្ប្រទាតា គុរុឝ្ឝ្រេឞ្ឋឝ្ឝិឞ្យឝ្ឝ្រេឞ្ឋស្តទាឝ្រិតះ៕

៧.	មិនមានជាតុណាផ្សេងទៀតវិសុទ្ធជាងចំណេះដឹងនោះទេនៅលើផែនដីនេះ គ្រូបង្រៀនគឺប្រសើរខ្ពង់ខ្ពស់ ដោយសារតែគាត់ផ្ដល់ចំណេះដឹងនោះទៅកាន់សិស្សគណរបស់គាត់ ហើយសិស្សដែលស្រវាស្រទេញនឹងការរៀនសូត្រ គ្រូគឺក្លាយជាជនដ៏សំខាន់បំផុត។

8.	शिष्यापराधान्सुबहून्मृष्यन्ति गुरवस्सदा ।
तुदन्ति गुरुचित्तानि दुष्टशिष्यास्त्वहर्निशम् ॥

**៨,	ឝិឞ្យាបរាធាន្សុពហូន្មឫឞ្យន្តិ គុរវស្សទា។**

តុទន្តិ គុរុចិត្តានិ ទុឞ្ដឝិឞ្យា ស្ត្វហនិ៌◌ឝម៑៕

៨.	គ្រូទាំងឡាយ តែងតែអភ័យទោសចំពោះកំហុសរបស់សិស្សគណជានិច្ច ប៉ុន្តែពួកសិស្សអាក្រក់តែងតែបង្ករបួសនៅក្នុងដួងចិត្តរបស់គ្រូ។

9. वेदान्तेष्वपि तस्यैव माहात्म्यं प्रतिपादितम् ।
गुरुशुश्रूषया यत्र शिष्यैः प्राप्तं महद्यशः ॥

៩, ទេវាន្តេម្វបិ តស៌្យៃវ មហាត្ម្យំ ប្រតិបាទិតម៑ៗ

គុរុគុស្រូមយា យត្រ គិ៌ម្យៃះ ប្រាប្តំ មហទ្យគះៗ|

៩. គុណាសម្បត្តិដ៏ខ្ពង់ខ្ពស់របស់គ្រូបង្រៀន ត្រូវបានរៀបរាប់សូម្បីតែនៅក្នុងគម្ពីរឧបនិស័ទ ជាទីដែលបានរៀបរាប់ចំនួនសិស្សគណទទួលបានកេរ្តិ៍ឈ្មោះតាមរយៈការបង្រៀនរបស់គ្រូរបស់ពួកគេនោះ។

10. पुराणेष्वन्यग्रन्थेषु गुरुसेवा प्रशंसिता ।
यतस्त एव सततं जयन्ति पृथिवीतले ॥

១០, បុរាណេម្វន្យគ្រន្ថេមុ គុរុសេវា ប្រគំសិតាៗ

យតស្ត ឯវ សតតំ ជយន្តិ ប្ឫថិវីតលេៗ|

១០. ភាពអស្ចារ្យនៃគ្រូបង្រៀនត្រូវបានកោតសរសើរក្នុងគម្ពីរបុរាណៈ និងគម្ពីរផ្សេងៗនៅឥណ្ឌា សម័យបុរាណដោយសារតែ មានតែគ្រូបង្រៀនទេដែលជាអ្នកឈ្នះនៅលើផែនដីនេះ។

11. मोक्षस्य मार्गो जटिलः तं दर्शयति सद्गुरुः ।
गुरुपूजैव विमला कार्या धीशालिभिर्नरैः ॥

១១, មោក្សស្យ មាគ៌ោ ជដិលះ តំ ទគ៌យតិ សទ្គុរុះៗ

គុរុបូជៃវ វិមលា កាយ៌ា ធីគាលិភិន៌ៃរះៗ|

11. មាគ៌ានៃមោក្ស គឺមានការលំបាកខ្លាំងណាស់ ប៉ុន្តែគ្រូអាចបង្ហាញផ្លូវនោះបាន។ ហេតុនេះហើយបានជាការគោរពបូជាគ្រូបង្រៀនគួរតែត្រូវបានអនុវត្តដោយវិមលជនទាំងឡាយនៅលើផែនដី។

12. अपृष्टमपि तं प्रश्नं शिष्यचित्तोद्भवं गुणी ।
जानाति सहसा स्वेन चक्षुषा गुरुरुत्तमः ॥

១២, អបូ្ឫដ្ឋមបិ តំ ប្រឝ្នំ ឝិឞ្យចិត្តោទ្ភវំ គុណីៈ

ជានាតិ សហសា ស្វេន ចក្ឞុឞា គុរុរុត្តមះ៕

១២. គ្រូបង្រៀនដែលឆ្នើមនិងមានជំនាញខ្ពស់ អាចមើលឃើញសូម្បីតែសំណួរនៅក្នុងចិត្តរបស់សិស្សដែលមិនបានសួរតាមរយៈខ្សែភ្នែករបស់ពួកគេ។

13. सनातनसुसंस्कृत्यामाचार्यास्सात्त्विकास्सदा ।
प्राधान्यमभजन्दिव्यमुन्नत्यां पुरुषोत्तमाः ॥

១៣, សនាតនសុសំស្កូត្យាមាចាយ៌ាស្សាត្ត្វិកាស្សទាៈ

ប្រាធាន្យមភជន្ទិវ្យមុន្នត្យាំ បុរុឞោត្តមាះ៕

១៣. ហេតុនេះហើយបានជានៅក្នុងប្រពៃណីនៃវប្បធម៌ដ៏ចំណាស់របស់ឥណ្ឌា គ្រូដែលបានកាន់កាប់នូវគុណសម្បត្តិសត្វិក ជាបុគ្គលដែលមានសារៈយ៉ាងសំខាន់ខ្លាំងដោយសារតែពួកគេ គឺជាអ្នកដែលល្អប្រសើរបំផុតក្នុងចំណោមមនុស្ស។

14. वेदान्तानां परस्ताद्ये श्रमणाचार्यसत्तमाः ।
तेषु जातास्तमोघ्नास्ते बौद्धधर्मप्रवर्तकाः ॥

១៤, វេទាន្តានាំ បរស្តាទ្យេ ឝ្រមណាចាយ៌សត្តមាះៈ

តេឞុ ជាតាស្តមោឃ្នាស្តេ ពៅទ្ធធម៌ប្រវត៌កាះ៕

១៤. បន្ទាប់ពីសម័យកាលឧបនិស័ទមក មានស្រមណាចារ្យជាច្រើននាក់បានកើតឡើងក្នុងប្រទេសឥណ្ឌា។ ភាគច្រើននៃពួកគេគឺជាអ្នកអប់រំតាមប្រពៃណីព្រះពុទ្ធសាសនា និងជាអ្នកលុបបំបាត់នូវមាយាការនិងអវិជ្ជា។

15. तेषु सर्वेषु सुगतश्शुद्धस्तत्त्वप्रदर्शकः ।

वैराग्यभावस्म्पन्नश्शास्तेत्यासीत्सुविश्रुतः ॥

១៥, តេឞុ សវ៌េឞុ សុគតឝ្ឝុទ្ធស្តត្ត្វប្រទឝ៌កះ។

វៃរាគ្យភាវស្ម្បន្នឝ្ឝាស្តេត្យាសីត្សុវិឝ្រុតះ៕

១៥. ក្នុងចំណោមអ្នកទាំងអស់នោះ ព្រះសុគតជាម្ចាស់ដ៏វិសុទ្ធជាអ្នកគាស់បង្ហាញអំពីសច្ចធម៌។ ព្រះអង្គពេញប្រៀបដោយវៃរាគ្យនិងមានព្រះកេរ្តិ៍ល្បីរន្ទឺសុសសាយ។ ព្រះអង្គត្រូវបានគេស្គាល់ ថាជា “សាស្តា”។

16. सद्गुरुस्सर्वभिक्षूणामद्वितीयस्तथागतः ।

बहून्मोहान्धकारान्यस्समुद्धरदसंशयम् ॥

១៦, សទ្គុរុស្សវ៌ភិក្ឞូណាមទ្វិតីយស្តថាគតះ។

ពហូន្មោហាន្ធការាន្យស្សមុទ្ធរទសំឝយម៑៕

១៦. ព្រះតថាគត គឺជាគ្រូដែលល្អបំផុតក្នុងចំណោមព្រះសង្ឃទាំងឡាយ។ ព្រះអង្គគឺជាប្រមុខនៃពួកភិក្ខុទាំងអស់ ព្រះអង្គបានសង្គ្រោះមនុស្សជាច្រើនឲ្យផុតពីភាពងងឹតនៃអវិជ្ជា។

17. राजपुत्रोऽपि शाक्यानामन्वयाब्धिसुधाकरः ।

तत्याज सकलं धीमान्दीनकल्याणतत्परः ॥

១៧, រាជបុត្រោ៓បិ ឝាក្យានាមន្វយាព្ធិសុធាករះ។

តត្យាជ សកលំ ធីមាន្ទីនកល្យាណតត្បរះ៕

១៧. ទោះបីជាព្រះអង្គជាព្រះអង្គម្ចាស់ប្រសូតនៅក្នុងវណ្ណៈក្សត្រិយ៍ ហើយទោះបីជាព្រះអង្គគឺ ដូចជាព្រះច័ន្ទនៅក្នុងមហាសមុទ្រនៃរាជវង្សសាក្យ ដ៏ខ្ពង់ខ្ពស់អស្ចារ្យក្តី, ព្រះអង្គ

បានចាកចេញ ពីអ្វីគ្រប់យ៉ាងសម្រាប់ជាប្រយោជន៍ដល់ប្រជាជនក្រីក្រគួរឱ្យអាសូរ និងតែងតែមានព្រះបំណង ជួយពួកគេដោយផ្តល់ឱ្យពួកគេនូវចំណេះដឹងពិតប្រាកដ ដោយការលុបបំបាត់អវិជ្ជាពោលគឺ ភាពល្ងង់ខ្លៅរបស់ពួកគេ។

18. पतितोद्धारकश्श्रीमान्सदा सद्धर्मशेवधिः ।

शास्तायमद्भुताचार्यः लोके सर्वत्र पूज्यते ॥

១៨, បតិតោទ្ធារកឝ្ឝ្រីមាន្សទា សទ្ធម៌ឝេវធិះ។

ឝាស្តាយមទ្ភុតាចាយ៌ះ លោកេ សវ៌ត្រ បូជ្យតេ៕

១៨. ព្រះអង្គជាអ្នកប្រោសប្រទានដល់មនុស្សគួរឱ្យអាសូរនិងអ្នកដែលមានវណ្ណៈទាប ជាឯកអគ្គបុគ្គល ជាអ្នកដែលប្រទាននូវរតនសម្បត្តិ ព្រះអង្គនេះហើយគឺជា “សាស្តា” គឺពិតជាគ្រូបង្រៀនដ៏ប្រសើរអស្ចារ្យ។ ហេតុនេះហើយបានជាព្រះអង្គត្រូវបានគេគោរពបូជានៅក្នុងពិភព លោកទាំងមូលរហូតមកដល់បច្ចុប្បន្ននេះ។

19. शास्त्रा बुद्धेन प्रथिताश्शताधिकसदुक्तयः ।

तास्सर्वास्सद्गुरूनन्यान्प्रैरयन्निति मे मतिः ॥

១៩, ឝាស្ត្រា ពុទ្ធេន ប្រថិតាឝ្ឝតាធិកសទុក្តយះ។

តាស្សវ៌ាស្សទ្គុរូនន្យាន្ប្រៃរយន្និតិ មេ មតិះ៕

១៩. ខ្ញុំជឿជាក់ថាមេរៀនដ៏ឧត្តុង្គឧត្តមរាប់រយដែលត្រូវបាន សម្តែងអធិប្បាយពន្យល់ដោយព្រះពុទ្ធជាម្ចាស់នោះ បានបំផុសគំនិតជាច្រើនផ្សេងទៀតនៅក្នុងប្រទេសឥណ្ឌា។

20. आनन्दस्य विनम्रस्य गुरुरासीत्तथागतः ।

उपालेः काश्यपस्यापि सुगतोऽयं महागुरुः ॥

២០,   អានន្ទស្យ ជិនម្រស្យ គុរុរាសីត្តថាគតះ។

ឧបាលេះ កាស្យបស្យាបិ សុគតោ៍យំ មហាគុរុះ៕

២០. ព្រះតថាគតគឺជាគ្រូដ៏ល្អរបស់ព្រះថេរាបសារមួយអង្គគឺព្រះអានន្ទ។ ដូចគ្នានេះដែរ ព្រះអង្គជាគ្រូរបស់ ព្រះឧបាលី និង ព្រះមហាកស្សប ។

21.   नगराटनसन्दर्भे शिष्या बुद्धस्य सात्विकाः ।

शताधिकायां संख्यायामाचार्येण सह स्थिताः ॥

២១,   នគរាដនសន្ទភេ៌ ឝិឞ្យា ពុទ្ធស្យ សាត្វិកាះ។

ឝតាធិកាយាំ សំខ្យាយាមាចាយ៌េណ សហ ស្ថិតាះ៕

២១. នៅពេលណាដែលព្រះពុទ្ធជាម្ចាស់ ចេញបិណ្ឌបាត្រសូមភិក្សា, ពេលណាព្រះអង្គចូលទៅតាមក្រុងនានា សាវ័ករាប់រយអង្គរបស់ព្រះអង្គបានរួមពុទ្ធដំណើរ។

22.   शरीरमिह दुःखस्य पदं मृत्युः प्रतीक्षते ।

संसारसागरे घोरे मज्जन्त्यज्ञानिनस्सदा ॥

២២,   ឝរីរមិហ ទុះខស្យ បទំ ម្ឫត្យុះ ប្រតីក្ឞតេ។

សំសារសាគរេ ឃោរេ មជ្ជន្ត្យជ្ញានិនស្សទា៕

22. ព្រះពុទ្ធជាម្ចាស់ បានប្រទានការបង្រៀនដ៏ល្អអស្ចារ្យជាច្រើន។ ព្រះអង្គបានសម្តែងថា រាងកាយមនុស្សនេះគឺជាទីលំនៅរបស់ការឈឺចាប់និងសេចក្តីទុក្ខលំបាក។ សេចក្តីស្លាប់តែងតែរង់ចាំនៅទីបំផុត។ មនុស្សល្ងង់ខ្លៅទាំងអស់ត្រូវបានជ្រមុជនៅក្នុងមហាសមុទ្រសំសារ នៃពិភពសម្ភារនិយមដោយពួកគេមិនដឹងថាអ្វីជាសច្ចភាពនៃពិភពលោកនេះទេ។

23. गेहान्धकारे तिष्टन्तश्शेरतेऽज्ञानपल्वले ।

विस्मृत्य सत्यं लोकस्य वित्ताण्वेषणतत्परा: ॥

២៣, គេហាន្ធការេ តិឞ្ឋន្តឝ្ឝេរតេៜ្ញានបល្វលេ៴

វិស្មឫត្យ សត្យំ លោកស្យ វិត្តាណ្វេឞណតត្បរាះ៴៕

២៣. ការរស់នៅក្នុងភាពងងឹតអន្ធការនៃជីវិតគ្រួសារ មនុស្សល្ងង់ខ្លៅ កំពុងដេកលក់ក្នុងភក់នៃមាយាការ។ ពួកគេភ្លេចសច្ចភាពនៃពិភពលោកនេះហើយជាប់វក់នៅក្នុងការស្វែងរកទ្រព្យ។

24. पत्नीसुतगृहाकृष्टा नानाव्यसनलोलुपा: ।

म्रियन्ते मनुजास्सर्वे मग्नास्संसारसागरे ॥

២៤, បត្នីសុតគ្ឫហាក្ឫឞ្ដា នានាវ្យសនលោលុបាះ៴

ម្រិយន្តេ មនុជាស្សវ៌េ មគ្នាស្សំសារសាគរេ៴៕

24. ដោយត្រូវបានចងទាញដោយប្រពន្ធ,កូន,ផ្ទះសម្បែង និងត្រូវបានដេកត្រាំនៅក្នុងប្រភេទផ្សេងៗនៃទម្លាប់អាក្រក់, មនុស្សទាំងអស់បានស្លាប់ដោយគ្មានការសម្រេចបាននូវប្រយោជន៍ សូម្បីដ៏តិចតួច ដូចជាពួកគេបានលិចលង់យ៉ាងជ្រៅនៅក្នុងសំសារ។

25. ज्ञानेन तद्विशुद्धेन हत्वाऽज्ञानं बुधोत्तम: ।

विपुलं सौख्यमाप्नोति वीर्यं शान्तिञ्च विन्दति ॥

២៥, ជ្ញានេន តទ្វិឝុទ្ធេន ហត្វាៜ្ញានំ ពុធោត្តមះ៴

វិបុលំ សៅខ្យមាប្នោតិ វីយ៌ំ ឝាន្តិញ្ច វិន្ទតិ៴៕

២៥. ប៉ុន្តែមនុស្សមានប្រាជ្ញាបានសម្លាប់នូវអវិជ្ជជាមួយនឹងបញ្ញាដ៏ឧត្តម ហើយទទួលបាននូវវិបុលសុខ កម្លាំង និងសន្តិភាពដ៏ពេញលេញនៅក្នុងជីវិតរបស់គេ។ អ្នកនោះហើយ គឺជា អ្នកប្រាជ្ញពិតប្រាកដ។

26. चित्तं प्रभास्वरं भिक्षो! चित्ते सर्वं प्रतिष्ठितम् ।

चित्तेन हि प्रसन्नेन कार्याणि कुरु सन्मते! ॥

២៦, ចិត្តំ ប្រភាស្វរំ ភិក្ខោ! ចិត្តេ សវ៌ំ ប្រតិឞ្ឋិតម៑។

ចិត្តេន ហិ ប្រសន្នេន ការ្យាណិ កុរុ សន្មតេ! ៕

២៦. ព្រះពុទ្ធជាម្ចាស់បានត្រាស់សម្តែងថា៖ ម្នាលភិក្ខុទាំងឡាយ! អ្វីៗទាំងឡាយមានចិត្តជាប្រមុខ អ្វីគ្រប់យ៉ាងត្រូវបានបង្កើតឡើងនៅក្នុងចិត្ត។ ហេតុនេះហើយ ចូរអប់រំចិត្តឲ្យបរិសុទ្ធ, ចូរធ្វើកិច្ចការដោយចិត្តស្ងប់សុខ។

27. शताधिकान्रिपून्जित्वाप्यज्ञो भवति दुर्जनः ।

आत्मानमात्मना जित्वा मोदते सज्जनस्सदा ॥

២៧, ឝតាធិកាន្រិបូន្ជិត្វាប្យជ្ញោ ភវតិ ទុជ៌នះ។

អាត្មានមាត្មនា ជិត្វា មោទតេ សជ្ជនស្សទា៕

២៧. ទុរជន គឺពេញដោយអវិជ្ជារមែងនឹងមិនសប្បាយចិត្តសូម្បីតែបន្ទាប់ពីឈ្នះសត្រូវរាប់រយនាក់របស់ពួកគេក៏ដោយ។ ប៉ុន្តែជនជាបណ្ឌិតគឺតែងតែសប្បាយចិត្តដោយសារតែបានទទួល ជ័យជម្នះលើចិត្តរបស់ខ្លួនហើយ ដូច្នេះឈ្មោះថាអាចយកឈ្នះខ្លួនឯង។

28. तृष्णावशंवदो भूत्वोद्दृप्तः कोपी विशङ्कितः ।

स्वचित्ते मोदमानेन सज्जनेन कथं समः ? ॥

២៨, ត្ឫ្ណាវឝំវទោ ត្ឫ្ណោ៌ន្យះ កោបី វិគហ៌ិតះ។

ស្វចិត្តេ មោទមានេន សជ្ជនេន កថំ សមះ?៕

២៨. មនុស្សម្នាក់ត្រូវបានចងទាញដោយតណ្ហា, អវិជ្ជា និងតែងតែលុះក្នុងអំណាចទោសៈ ឯម្នាក់ទៀត គឺជាមនុស្សម្នាក់ដែលជាបណ្ឌិតតែងសប្បាយរីករាយក្នុងចិត្តរបស់គេជានិច្ច។ តើយើងអាចប្រៀបធៀបមនុស្សពីរនាក់នេះយ៉ាងដូចម្តេច? អរិយជនគឺតែងតែមានភាពផ្សេងគ្នាពីជនធម្មតា។

29. मनुष्यजीवने तावद्घटते घटनाद्वयम् ।

काचित्सुखप्रदायिनी चेदन्या शोकप्रदायिनी ॥

២៩, មនុឞ្យជីវនេ តាវទ្ឃដតេ ឃដនាទ្វយម៑។

កាចិត្សុខប្រទាយិនី ចេទន្យា ឝោកទាយិនី៕

២៩. មានឧប្បត្តិហេតុពីរប្រភេទ តែងតែកើតឡើងនៅក្នុងជីវិតរបស់មនុស្ស។ មួយជាឧប្បត្តិហេតុជាមង្គលនាំឲ្យយើងសប្បាយរីករាយ, មួយទៀតគឺឧប្បត្តិហេតុដែលផ្តល់ឱ្យយើងនូវភាពឈឺចុកចាប់ និងទុក្ខលំបាក។

30. सर्वमेतन्मनुष्याणां चित्तस्यैव परिप्लवः ।

प्रीणातु सहसा चित्तं तस्माद्यत्नेन बुद्धिमान् ॥

៣០, សវ៌មេតន្មនុឞ្យាណាំ ចិត្តស្យៃវ បរិបល្លវះ។

ប្រីណាតុ សហសា ចិត្តំ តស្មាទ្យត្នេន ពុទ្ធិមាន៑៕

៣០. ប៉ុន្តែតាមពិតការសប្បាយ និងការឈឺចាប់ទាំងនេះ គឺជាការបង្កើតឡើងដោយចិត្តរបស់យើងតែប៉ុណ្ណោះ។ ព្រោះហេតុនេះហើយបានជាមនុស្សមានប្រាជ្ញាតែងតែរក្សាចិត្តរបស់ខ្លួនដោយសេចក្តីស្ងប់ និងសុភមង្គល។

31. इत्यादीनुपदेशान्यो ददौ पतितपावनः ।

बुद्धश्शीलसमाधिभ्यां महागुरुरिति स्मृतः ॥

៣១, ឥត្យាទីនុបទេឝាន្យោ ទទៅ បតិតបាវនះ។

ពុទ្ធឝ្ឝីលសមាធិភ្យាំ មហាគុរុរិតិ ស្មតះ៕

៣១. អគ្គបុគ្គលដែលបានផ្តល់ការបង្រៀនដ៏អស្ចារ្យពួកយើងគឺព្រះសម្ពុទ្ធជាម្ចាស់។ ហេតុនេះហើយបានជាខ្ញុំមានអារម្មណ៍ថាព្រះពុទ្ធជាម្ចាស់ប្រសើរលើសពីអ្នកដទៃដោយ សីល និងសមាធិ ព្រះអង្គគឺពិតជាគ្រូដ៏ប្រសើរខ្ពង់ខ្ពស់បំផុតរបស់ប្រទេសឥណ្ឌា។

32. गुरवस्सात्त्विकास्सर्वे शिष्यवात्सल्यसिन्धवः ।

रेजिरे भारते राष्ट्रे बुद्धस्तेषु महागुरुः ॥

៣២, គុរវស្សាត្ត្វិកាស្សវ៌េ ឝិឞ្យវាត្សល្យសិន្ធវះ។

រេជិរេ ភារតេ រាឞ្ដ្រេ ពុទ្ធស្តេឞុ មហាគុរុះ៕

32. ជាការពិត គ្រូនៅក្នុងប្រទេសឥណ្ឌាសុទ្ធតែប្រសើរដែលបានគ្រប់គ្រងតណ្ហារបស់ខ្លួន និងកាន់យកនូវគុណធម៌សត្វិក (គុណធម៌សេចក្តីថ្លៃថ្នូរខ្ពស់បំផុត) ពួកគេទាំងអស់ត្រូវបាន ប្រៀបប្រដូចជាមហាសមុទ្រនៃសេចក្តីស្រឡាញ់សម្រាប់សិស្សគណទាំងឡាយ។ គ្រូជាច្រើននោះ បានកើតឡើងបំភ្លឺក្នុងរដ្ឋឥណ្ឌាជំនាន់ដើមប៉ុន្តែព្រះពុទ្ធជាម្ចាស់គឺពិតជាគ្រូដែលផ្សេងពីគេ និងប្រសើរខ្ពង់ខ្ពស់ក្នុងចំណោមពួកគេ។

33. बुद्धाचार्येणोपदिष्टं सूत्रं विनयमेव च ।

लक्षाधिकसहस्रेषु तच्छिष्या ह्यग्रहीषत ॥

៣៣, ពុទ្ធាចាយ៌េណោបទិឞ្ដំ សូត្រំ វិនយមេវ ច។

លក្ឞាធិកសហស្រេឞុ តច្ឆិឞ្យា ហ្យគ្រហីឞត៕

33. ការបង្រៀនដ៏ថ្លៃថ្លាល្អវិសុទ្ធអំពីព្រះសូត្រនិង ព្រះវិន័យ ដែលបង្រៀនដោយព្រះពុទ្ធបរមគ្រូជាម្ចាស់ ត្រូវបានទទួលយកដោយសាវ័ករបស់ព្រះអង្គរាប់លាននាក់នៅក្នុងប្រទេសឥណ្ឌា។

ពុទ្ធជីវនគីតម៑

(ចម្រៀងពុទ្ធជីវនិទាន)

बुद्धं शुद्धं वन्देऽहम्
तं जगदानन्दकरं वन्दे

ពុទ្ធំ ឝុទ្ធំ វន្ទេ'ហម៑

តំ ជគទានន្ទករំ វន្ទេ

मायादेवीगजस्वप्नफलं
लुम्बिनीवनजातं
असितवचोपरिपूरकं
शाक्यान्वयाग्रतारकम्

មាយាទេវីគជស្វប្នផលំ

លុម្ពិនីវនជាតំ

អសិតវចោបរិបូរកំ

ឝាក្យាន្វយាគ្រតារកម៑

बुद्धं शुद्धं वन्देऽहम्
तं जगदानन्दकरं वन्दे

ពុទ្ធំ ឝុទ្ធំ វន្ទេ'ហម៑

តំ ជគទានន្ទករំ វន្ទេ

अधिगतसमस्तविद्यानिचयं
यशोधराप्रियवल्लभं
राहुलजनकं
रागमयं
सकलभोगपरितोषितहृदयम्

អធិគតសមស្តវិទ្យានិចយំ

យឝោធរាប្រិយវល្លភំ

រាហុលជនកំ

រាគមយំ

សកលលោកបរិតោឞិតហ្ឫទយម៑

बुद्धं शुद्धं वन्देऽहं
तं जगदानन्दकरं वन्दे।

ពុទ្ធំ ឝុទ្ធំ វន្ទេ'ហម៑

តំ ជគទានន្ទករំ វន្ទេ ។

राजवीथीषु दुःखदर्शनं
आदौ नु बुद्धयाचकं
पश्चात्
व्याधिग्रस्तं पुरुषं
तत्पश्चात् मृतकलेवरं

រាជវីថីឞុ ទុះខទឝ៌នំ

អាទៅ នុ ពុទ្ធយាចកំ

បឝ្ចាត៑

វ្យាធិគ្រស្តំ បុរុឞំ

តត្បឝ្ចាត៑ ម្ឫតកលេវរំ

बुद्धं शुद्धं वन्देऽहं
तं जगदानन्दकरं वन्दे।
ពុទ្ធំ ឝុទ្ធំ វន្ទេ'ហម៑

តំ ជគទានន្ទករំ វន្ទេ ៕

पश्चात् दृष्ट्वा
यतिं प्रशान्तं
वैराग्यभावनिश्चलं
विसृष्टपत्नीप्रियसुतं वरं
सत्यमार्गाण्वेषकं
បឝ្ចាត៑ ទ្ឫឞ្ដ្វា

យតឹ ប្រឝាន្តំ

វៃរាគ្យភាវនិឝ្ចលំ

វិស្ឫឞ្ដបត្នីប្រិយសុតំ វរំ

សត្យមាគ៌ាណ្វេឞកំ

बुद्धं शुद्धं वन्देऽहं
तं जगदानन्दकरं वन्दे।
ពុទ្ធំ ឝុទ្ធំ វន្ទេ'ហម៑

តំ ជគទានន្ទករំ វន្ទេ ៕

अनशननिन्दक !
तथागत!
सत्यधर्मसन्देशक !
सुगत!
मध्यममार्गाण्वेषक!

बुद्ध!
आर्यसत्यविज्ञानविशुद्ध!
អនឝននិន្ទក!

តថាគត!

សត្យធម៌សន្ទេឝក!

សុគត!

មធ្យមមាគ៌ាណ្វេមក!

ពុទ្ធ!

អាយ៌សត្យវិជ្ញានវិឝុទ្ធ!

बुद्ध!
शुद्ध!
पालय मां
विज्ञानविशुद्ध!
पालय माम्।
ពុទ្ធ!

ឝុទ្ធ!

បាលយ មាំ

វិជ្ញានវិឝុទ្ធ!

បាលយ មាម៑ ។

मृगवने प्रथमोपदेशक!
मारविजिताज्ञाननाशक!
ख्यातसत्या-सत्यशोधक!
बिम्बिसारप्रिय! विनायक!
ម្ឫគវនេ ប្រថមោបទេឝក!

មារវិជិតាជ្ញាននាឝក!

ខ្យាតសត្យ-សត្យឝោធក!

ពិម្ពិសារប្រិយ វិនាយក!

बुद्ध!
शुद्ध!
पालय माम्।
विज्ञानविशुद्ध!
पालय माम्।

ពុទ្ធ!

ឝុទ្ធ!

បាលយ មាំ

វិជ្ញានវិឝុទ្ធ!

បាលយ មាម៑ ។

ពុទ្ធជីវនគីតម៏

(ចម្រៀងពុទ្ធជីវនិទាន)

ខ្ញុំសូមក្រាបថ្វាយបង្គំប្រណម្យវន្ទាឆ្ពោះព្រះភគវាទ្រង់ញាណសម្ពុទ្ធមកុដច្បងដ៏ឧត្តមវិសុទ្ធបំផុតលោក ព្រះអង្គជាអ្នកប្រទាននូវពន្លឺសុខក្សេមក្សាន្តដល់សកលលោកទាំងមូល

*ព្រះអង្គបានចាប់បដិសន្ធិឡើងប្រៀបដូចជាផ្លែផល្លាដ៏មានឱជារសនៃសុបិននិមិត្តរបស់ព្រះវររាជមាតាព្រះអង្គ, គឺព្រះនាង**មាយាទេវី**ទ្រង់យល់សុបិនឃើញស្វេតហត្ថី (សត្វដំរីស) ព្រះអង្គដែលទ្រង់បានប្រសូត ហើយក្នុងសួនឧទ្យាន**លុម្ពិនី**នឹងមានខ្សែព្រះជន្មជីពដូចជាពាក្យទំនាយរបស់មហាឥសី**អសិត** ទ្រង់ជា ផ្កាយដែលរះយ៉ាងត្រចះត្រចង់ក្នុង**សាក្យវង្ស***

ខ្ញុំសូមក្រាបថ្វាយបង្គំប្រណម្យវន្ទាឆ្ពោះព្រះភគវាទ្រង់ញាណសម្ពុទ្ធមកុដច្បងដ៏ឧត្តមវិសុទ្ធបំផុតលោក ព្រះអង្គជាអ្នកប្រទាននូវពន្លឺសុខក្សេមក្សាន្តដល់សកលលោកទាំងមូល

*កាលពីកុមារភាព ព្រះអង្គបានទទួលនូវចំណេះដឹងគ្រប់ប្រភេទដោយប្រពៃ ទ្រង់ជាព្រះភស្តាជាទី ស្រឡាញ់នៃអគ្គមហេសីរបស់ព្រះអង្គគឺព្រះនាង**យសោធរា** ព្រមទាំងជាព្រះរាជបិតានៃ**រាហុលកុមារ** ជាទីស្រឡាញ់ជាប់ចិត្តនៃជនទាំងពួង ទ្រង់បានបំពេញព្រះហឫទ័យដោយសេចក្តីត្រេកត្រអាលនឹង ប្រណីតភាពទាំងឡាយក្នុងជីវិត*

ខ្ញុំសូមក្រាបថ្វាយបង្គំប្រណម្យវន្ទាឆ្ពោះព្រះភគវាទ្រង់ញាណសម្ពុទ្ធមកុដច្បងដ៏ឧត្តមវិសុទ្ធបំផុតលោក ព្រះអង្គជាអ្នកប្រទាននូវពន្លឺសុខក្សេមក្សាន្តដល់សកលលោកទាំងមូល។

*បន្ទាប់មក ព្រះអង្គបានទតឃើញរាល់ការឈឺចាប់ទាំងឡាយនៃជីវិតនៅតាមរាជវិថីនៃរាជធានី**កបិលពស្តុ** ជាដំបូងទ្រង់ទតឃើញស្មូមចាស់ជរាម្នាក់ បន្ទាប់មកទៀតទ្រង់ទតឃើញបុរសម្នាក់ដែលជំងឺដម្កាត់ កំពុងបៀតបៀន ហើយបន្ទាប់ពីនោះព្រះអង្គបានទតឃើញនូវសាកសពដែលមានជីវិតទៅប្រាសហើយ*

ខ្ញុំសូមក្រាបថ្វាយបង្គំប្រណម្យវន្ទាឆ្ពោះព្រះភគវាទ្រង់ញាណសម្ពុទ្ធមកុដច្បងដ៏ឧត្តមវិសុទ្ធបំផុតលោក ព្រះអង្គជាអ្នកប្រទាននូវពន្លឺសុខក្សេមក្សាន្តដល់សកលលោកទាំងមូល

ក្រោយពីនោះមកទ្រង់បានទតឃើញនូវបព្វជិតដែលមានឥន្ទ្រីយ៍ស្រគត់ស្រគំ ពោរពេញដោយសន្តិភាព វិរាគ គឺសេចក្តីនឿយណាយចាប់ផ្តើមកើតឡើងចំពោះទ្រង់ ព្រះអង្គបានបោះបង់ចោលនូវមហេសីជាទី ស្រឡាញ់ព្រមទាំងព្រះឱរសបណ្តូលចិត្ត ហើយបានចាប់ផ្តើមចេញស្វែងរកមាគ៌ានៃសច្ចធម៌

ខ្ញុំសូមក្រាបថ្វាយបង្គំប្រណម្យវន្ទាឆ្ពោះព្រះភគវាទ្រង់ញាណសម្ពុទ្ធមកុដច្បងដ៏ឧត្តមវិសុទ្ធបំផុតលោក ព្រះអង្គជាអ្នកប្រទាននូវពន្លឺសុខក្សេមក្សាន្តដល់សកលលោកទាំងមូល

បពិត្រព្រះតថាគត! ព្រះអង្គបានឈ្វេងយល់ច្បាស់ពីភាពគ្មានប្រយោជន៍នៃការប្រព្រឹត្តរឹងត្អឹងពោលគឺទុក្ករកម្មហើយ

បពិត្រព្រះសុគត! ព្រះអង្គបានបើកបង្ហាញនូវសច្ចភាពនិង ធម្មដ៏ប្រសើរ

បពិត្រព្រះសម្ពុទ្ធ! ព្រះអង្គបានស្វែងរកឃើញនូវមាគ៌ាបតិបត្តិបែបកណ្តាលពោលគឺ **មជ្ឈិមបដិបទា** ដ៏វិសុទ្ធ ព្រះអង្គបានញ៉ាំងលោកទាំងមូលឲ្យភ្លឺស្វាងដោយចតុរារិយសច្ចៈដែលទ្រង់បានស្វែងយល់ដោយពោធិញ្ញាណដ៏វិមុត្តិ

បពិត្រព្រះសម្ពុទ្ធ ជាឯកអគ្គបុគ្គលក្នុងលោក! សូមអភិបាលរក្សានូវខ្ញុំ

បពិត្រព្រះទ្រង់ញាណដ៏វិមុត្តិ! សូមនាំឲ្យខ្ញុំបានយល់ពីមាគ៌ារបស់ព្រះអង្គផង។

ព្រះអង្គបានប្រទាននូវបឋមទេសនាក្នុងព្រៃ **ឥសិបតនមិគទាយវ័ន** ទ្រង់មានជ័យជំនះលើមារាធិរាជហើយ ព្រះអង្គជាបុគ្គលដែលជ្រាបច្បាស់នូវរាល់ការពិតនិងការមិនពិត ទ្រង់ជាព្រះជីតុនជាទីគោរពស្រឡាញ់នៃព្រះបាទមគធសេនីយរាជ**ពិម្ពិសារ** ព្រះអង្គជាអ្នកដឹកនាំដ៏ប្រសើរបំផុតនៃគណៈសង្ឃ

បពិត្រព្រះសម្ពុទ្ធ ជាឯកអគ្គបុគ្គលក្នុងលោក! សូមអភិបាលរក្សានូវខ្ញុំ

បពិត្រព្រះទ្រង់ញាណដ៏វិមុត្តិ! សូមនាំឲ្យខ្ញុំបានយល់ពីមាគ៌ារបស់ព្រះអង្គផង។



សាស្ត្រាចារ្យបណ្ឌិត **ឧបេន្ទ្រ វ៉ាច**

ទទួលវត្ថុអនុស្សាវរីយ៍អំពី**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស**

សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា

នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ



សាស្ត្រាចារ្យបណ្ឌិត **ឧបេន្ទ្រ រ៉ាវ**

ទទួលវត្ថុអនុស្សាវរីយ៍អំពី**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស**

សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា

នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ